**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ....០...៨..៦........សកបយ

ភ្នំពេញ.ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០២

## ប្រកាស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៧ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស-រកម-០៦៩៩-០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ-បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការ បញ្ជូនពលករខ្មែរទៅធ្វើការនៅឯបរទេស

- បានឃើញកំហុសរបស់ក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ ស្តីពីការមិនបានអនុវត្តប្រការ៣នៃប្រកាស លេខ០៨០ សកបយ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០១និងប្រការ៦នៃកិច្ចសន្យាស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសក្រិច រវាងក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ ។

## សំរេច

ប្រការ ១: ត្រូវបានចាត់ទុកជានិរាករណ៍នូវប្រកាស លេខ ០៨០ សកបយ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីការអនុញ្ញាតិឱ្យក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ C.C.A.Co., LTD (CAMBODIAN CONSULTANT ASSOCIATE ) ធ្វើការបណ្តុះបណ្តាល និងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសក្រិច ។

ប្រការ ២: មេដឹកនាំទាំងអស់របស់ក្រុមហ៊ុន ស៊ី សី អេ ចំកាត់ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ការខូចខាតដែលក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ បានបង្កឡើង ។

ប្រការ ៣: បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤: អគ្គនាយដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ និងខុទ្ទកាល័យត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

- -ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- -ឯកសារ-កាលប្បវត្តិ